# សូមកុំភ្លេចចុះបញ្ជីឈ្មោះកូនរបស់អ្នក!



ចុះបញ្ជីឈ្មោះតាមអនឡាញ ហើយឥតគិតថ្លៃទេ!





សូមចុះបញ្ជីឈ្មោះកូនរបស់អ្នកនៅតាម

**www.cbs.sa.gov.au/births-deaths-marriages**




## វាពិតជាមានសារៈសំខាន់ណាស់! មន្ទីរពេទ្យមិនធ្វើកិច្ចការនេះសម្រាប់អ្នកទេ។

អ្នកត្រូវតែចុះបញ្ជីឈ្មោះកូនរបស់អ្នកក្នុងរយៈពេល 60 ថ្ងៃ បន្ទាប់ពីសម្រាលកូនហើយ។ ប្រសិនបើអ្នកមិនចុះបញ្ជីឈ្មោះកូនរបស់អ្នកទេ អ្នកមិនអាចដាក់ពាក្យសុំប្រាក់បំណាច់ Centrelink ជាក់លាក់បានទេ។ ដូចគ្នានេះផងដែរ ប្រសិនបើកំណើតរបស់កូនអ្នកមិនបានចុះបញ្ជីឈ្មោះទេ អ្នកមិនអាចទទួលបានសំបុត្រកំណើតសម្រាប់ពួកគេទេ។



Government of South Australia
Attorney-General's Department

# នេះជារបៀបចុះបញ្ជីឈ្មោះកូនរបស់អ្នកតាមអនឡាញ



### 1 ត្រូវប្រាកដថាឪពុកម្ដាយទាំងពីរ មានទូរស័ព្ទចល័តដែលអាចទទួលបានសារ **SMS**។

ប្រសិនបើឪពុកម្ដាយទាំងពីរ មិនមានទូរស័ព្ទចល័តទេ អ្នកនៅតែអាចចុះបញ្ជីឈ្មោះកូនរបស់អ្នកតាមអនឡាញ។ នៅចុងបញ្ចប់នៃដំណើរការចុះបញ្ជីឈ្មោះនេះ អ្នកនឹងទទួលបានអ៊ីម៉ែលដែលមានឯកសារ PDF មួយច្បាប់ ដែលត្រូវបោះពុម្ពចេញ និងចុះហត្ថលេខាដោយឪពុកម្ដាយទាំងពីរ។



### 2 រៀបចំឯកសារអត្តសញ្ញាណប័ណ្ណ **ID** សម្រាប់ឪពុកម្ដាយទាំងពីរ

មុនពេលចូលប្រើអនឡាញ អ្នកត្រូវមានឯកសារជារូបភាពដែលបានស្កេន ឬអាចថតរូបលិខិតឆ្លងដែនអូស្ត្រាលី ប័ណ្ណបើកបរអូស្ត្រាលី ឬប័ណ្ណ Centrelink និងប័ណ្ណ Medicare សម្រាប់ឪពុកម្ដាយទាំងពីរ។

ប្រសិនបើឪពុកម្ដាយទាំងពីរ មិនមានឯកសារអត្តសញ្ញាណប័ណ្ណ ID ដែលតម្រូវនោះ  អ្នកនៅតែអាចចុះបញ្ជីឈ្មោះកូនរបស់អ្នកតាមអនឡាញ។ បន្ទាប់មកអ្នកនឹងទទួលបានអ៊ីម៉ែលដែលមានឯកសារ PDF មួយច្បាប់ ដែលត្រូវបោះពុម្ពចេញ និងចុះហត្ថលេខាដោយឪពុកម្ដាយទាំងពីរ។

### 3 ត្រូវប្រាកដថាអ្នកបានយល់ព្រមចំពោះឈ្មោះរបស់កូន

វាមានសារសំខាន់ដែលថា អ្នកបានយល់ព្រមចំពោះឈ្មោះរបស់កូន។ ប្រសិនបើអ្នកផ្លាស់ប្ដូរគំនិតរបស់អ្នក បន្ទាប់ពីអ្នកបានចុះបញ្ជីឈ្មោះកូនរបស់អ្នកហើយ ការនេះអាចបណ្ដាលឱ្យមានការពន្យារពេល។

### 4 ត្រូវប្រាកដថា អ្នកមានព័ត៌មានអំពីកូន និងឪពុកម្ដាយ

អ្នកអាចស្វែងរកព័ត៌មាននេះមួយចំនួន ឧទាហរណ៍ ព័ត៌មានលម្អិតអំពីទម្ងន់នៅពេលកើតរបស់ទារក វេជ្ជបណ្ឌិត/ឆ្មប - នៅក្នុងសៀវភៅខៀវ ដែលមន្ទីរពេទ្យផ្ដល់ជូនអ្នក។

### 5 សូមចូលទៅកាន់ **www.cbs.sa.gov.au/births-deaths-marriages** ដើម្បីចុះបញ្ជីឈ្មោះកំណើតកូន

អ្នកមិនចាំបាច់បំពេញសំណុំបែបបទតាមអនឡាញនៅក្នុងពេលតែមួយទេ។ នៅពេលអ្នកបានចាប់ផ្ដើមសំណុំបែបបទតាមអនឡាញ អ្នកនឹងទទួលបានលេខឯកសារយោងមួយ។ អ្នកអាចប្រើលេខឯកសារយោងនេះ ដើម្បីបន្តដំណើរការពីកន្លែងដែលអ្នកបានផ្អាករហូតដល់ទៅ 48 ម៉ោង។

ប្រសិនបើអ្នកមិនមានមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិតទេ សូមហៅទូរស័ព្ទលេខ 131 882 ហើយយើងនឹងផ្ញើសំណុំបែបបទជាសណ្ឋានក្រដាសជូនអ្នក។



### 6 ការបញ្ជាទិញសំបុត្រកំណើត

អ្នកអាចជ្រើសរើសដើម្បីបញ្ជាទិញសំបុត្រកំណើតក្នុងពេលតែមួយ ខណៈពេលចុះបញ្ជីឈ្មោះកូនរបស់អ្នកតាមអនឡាញ។ អ្នកមិនចាំបាច់ត្រូវតែបញ្ជាទិញសំបុត្រកំណើតទេ ហើយអ្នកអាចធ្វើការនេះបាននៅពេលក្រោយទៀត ប្រសិនបើអ្នកប្រាថ្នា។ ដើម្បីបញ្ជាទិញសំបុត្រកំណើត អ្នកត្រូវមានកាត Visa (វីសា) ឬ Mastercard (ម៉ាស្ទ័រ)។

### 7 ឆ្លើយតបទៅនឹងសារ **SMS**

ឪពុកម្ដាយទាំងពីរ នឹងទទួលបានការផ្ញើសារ SMS មួយ។ ឪពុកម្ដាយទាំងពីរ ត្រូវឆ្លើយតបនឹងសារ SMS នោះ ដើម្បីបញ្ជាក់ថាពួកគេជាឪពុកម្ដាយរបស់កូន មុនពេលចុះបញ្ជីឈ្មោះកូន ហើយអ្នកអាចទទួលបានសំបុត្រកំណើត។



**Government of South Australia**
Attorney-General's Department